# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា**

លេខ......៤៦៩២/២៤......អ គ រ

ថ្ងៃ ......... ២ កើត ខែ ........ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨

រាជធានីភ្នំពេញ ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ២០២៤

## ជម្រាបមក

## លោក លោកស្រី ប្រធានលេខាធិការដ្ឋាន នាយកដ្ឋាន សាខា និងការិយាល័យគយនិងរដ្ឋាករ

**កម្មវត្ថុ ៖** ការដាក់ឱ្យប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងភាពជឿជាក់លើធុរជន ជំនាន់ថ្មី (Trader Credibility Management System – TCMS 4.0) និងនីតិវិធីនៃកិច្ចដំណើរការស្នើសុំចុះបញ្ជីធុរជនក្នុងទម្រង់អេឡិចត្រូនិកតាមប្រព័ន្ធគ្រប់គ្រងភាពជឿជាក់លើធុរជន (TCMS)។

**យោង ៖**
- សារាចរណែនាំលេខ ០០៧ សហវ ចុះថ្ងៃទី៧ ខែធ្នូ ឆ្នាំ២០០៧ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ស្ដីពីការអនុវត្តគោលនយោបាយនៃកិច្ចសម្រួលពាណិជ្ជកម្ម តាមរយៈការគ្រប់គ្រងហានិភ័យ
- សេចក្ដីណែនាំលេខ ១១៣៥/១៧ អគរ ចុះថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០១៧ របស់អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា ស្ដីពីការពង្រឹងប្រសិទ្ធភាពការងារចុះបញ្ជីក្រុមហ៊ុននាំចេញ-នាំចូល ចូលទៅក្នុងប្រព័ន្ធគ្រប់គ្រងហានិភ័យគយ។

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបមកលោក លោកស្រីជ្រាបថា ដើម្បីប្រសិទ្ធភាពការងារគ្រប់គ្រងហានិភ័យគយ ក្នុងគោលដៅជំរុញបន្ថែមទៀតនូវកិច្ចសម្រួលពាណិជ្ជកម្មនិងទំនើបកម្មគយ អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា សម្រេចដាក់ឱ្យប្រើប្រាស់ជាផ្លូវការប្រព័ន្ធគ្រប់គ្រងភាពជឿជាក់លើធុរជន ជំនាន់ថ្មី (Trader Credibility Management System – TCMS 4.0) និងនីតិវិធីកិច្ចដំណើរការស្នើសុំចុះបញ្ជីធុរជនក្នុងទម្រង់អេឡិចត្រូនិកតាមប្រព័ន្ធ TCMS ដូចមានក្នុងឧបសម្ព័ន្ធភ្ជាប់ជាមួយលិខិតនេះ។

អាស្រ័យហេតុនេះ សូមលោក លោកស្រីចាត់ចែងផ្សព្វផ្សាយ និងអនុវត្តតាមខ្លឹមសារនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០២៥ តទៅ។

សូមលោក លោកស្រី ទទួលនូវការស្រឡាញ់រាប់អានពីខ្ញុំ

**រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី**
**អគ្គនាយកគយនិងរដ្ឋាករកម្ពុជា**

បណ្ឌិត គុណ ញឹម

**ចម្លងជូន ៖**
- ខុទ្ទកាល័យឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ "ដើម្បីជូនជ្រាប"
- សភាពាណិជ្ជកម្មកម្ពុជា "ដើម្បីសហការផ្សព្វផ្សាយ"
- ឯកសារ - កាលប្បវត្តិ

## ឧបសម្ព័ន្ធ ១

(អមភ្ជាប់លិខិតលេខ ៥៦៩៧/២៤ អគរ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤ របស់អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា)

# នីតិវិធីនៃកិច្ចដំណើរការស្នើសុំចុះបញ្ជីធុរជនក្នុងទម្រង់អេឡិចត្រូនិក តាមប្រព័ន្ធគ្រប់គ្រងភាពជឿជាក់លើធុរជន (TCMS)

អនុលោមតាមសារាចរណែនាំលេខ ០០៧ សហវ ចុះថ្ងៃទី០៧ ខែធ្នូ ឆ្នាំ២០០៧ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ស្តីពីការអនុវត្តគោលនយោបាយនៃកិច្ចសម្រួលពាណិជ្ជកម្មតាមរយៈការគ្រប់គ្រងហានិភ័យ, សេចក្តីណែនាំលេខ ១១៣៥/១៧ អគរ ចុះថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០១៧ របស់អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា ស្តីពីការពង្រឹងប្រសិទ្ធភាពការងារចុះបញ្ជីក្រុមហ៊ុននាំចេញ-នាំចូល ចូលក្នុងប្រព័ន្ធគ្រប់គ្រងហានិភ័យគយ និងក្នុងគោលបំណងចូលរួមអនុវត្តក្របខ័ណ្ឌគោលនយោបាយសេដ្ឋកិច្ចនិងសង្គមឌីជីថលកម្ពុជា ដើម្បីជួយសម្រួលកិច្ចពាណិជ្ជកម្ម អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា (**អគរ**) សូមធ្វើការណែនាំអំពីនីតិវិធីនៃកិច្ចដំណើរការស្នើសុំចុះបញ្ជីធុរជនក្នុងទម្រង់អេឡិចត្រូនិក តាមប្រព័ន្ធគ្រប់គ្រងភាពជឿជាក់លើធុរជន (TCMS) ជំនាន់ថ្មី ដូចខាងក្រោម៖

## I. **ធុរជនជាកម្មវត្ថុនៃប្រព័ន្ធ** TCMS

- ក្រុមហ៊ុនថ្មីដែលមានសកម្មភាពនាំចេញ-នាំចូលទំនិញក្នុងដែនគយទាំងអស់ ជាកម្មវត្ថុនៃការស្នើសុំចុះបញ្ជីក្នុងប្រព័ន្ធគ្រប់គ្រងភាពជឿជាក់លើធុរជន (TCMS)
- ក្រុមហ៊ុនដែលមានឈ្មោះក្នុងបញ្ជីធុរជនរកមិនឃើញ (Unknown) ផ្អែកតាមរបាយការណ៍ចុះអង្កេតទីតាំង/អាសយដ្ឋាន ហើយរកមិនឃើញ ដោយមន្ត្រីគយនិងរដ្ឋាករមូលដ្ឋាន និងត្រូវបានវាយតម្លៃថាជាក្រុមហ៊ុនមានហានិភ័យខ្ពស់ដោយនាយកដ្ឋានសវនកម្មគយ។

## II. **នីតិសម្បទា និងដំណើរការនៃការស្នើសុំ**

### **១.** បុគ្គលដែលមាននីតិសម្បទា

- ម្ចាស់ក្រុមហ៊ុន (ភ្ជាប់ជាមួយនូវអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរឬលិខិតឆ្លងដែន) ឬ
- បុគ្គលិកក្រុមហ៊ុនជាតំណាងស្របច្បាប់ដែលបានទទួលសិទ្ធិ (ភ្ជាប់លិខិតផ្ទេរសិទ្ធិនិងប័ណ្ណសម្គាល់បុគ្គលិក)
- ដេីងសាគយមានការអនុញ្ញាត (ភ្ជាប់លិខិតផ្ទេរសិទ្ធិ និងប័ណ្ណសម្គាល់ដេីងសាគយ)។

### **២.** កិច្ចដំណើរការនៃការស្នើសុំតាមប្រព័ន្ធ TCMS

- ម្ចាស់ក្រុមហ៊ុន ឬតំណាង ឬដេីងសាគយ មាននីតិសម្បទាត្រូវស្នើសុំបង្កើតគណនីសម្រាប់ចូលប្រើប្រាស់ប្រព័ន្ធតាមរយៈតាមអាសយដ្ឋាន https://rm.customs.gov.kh/TCMS
- គណនីចូលប្រើប្រព័ន្ធ និងពាក្យសំងាត់ ដែលទទួលបានពីប្រព័ន្ធត្រូវរក្សាទុកដាក់ឱ្យមានសុវត្ថិភាពដោយស្មារតីទទួលខុសត្រូវ

- បំពេញទិន្នន័យក្នុងប្រអប់ព័ត៌មាននៃប្រព័ន្ធ TCMS តាមរយៈអាសយដ្ឋាន ដែលបានកំណត់ (https://rm.customs.gov.kh/TCMS) តាមលំដាប់លំដោយ ដោយរើសប្រភេទសំណើតាមតម្រូវការ និងភ្ជាប់នូវឯកសារគាំទ្រនានាក្នុងទម្រង់អេឡិចត្រូនិក
- ត្រូវអនុវត្តការស្នើសុំដូចមានចែងក្នុងសេចក្តីណែនាំលេខ ១១៣៥/១៧ អគរ ចុះថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០១៧ ដូចយោងខាងលើ និងឯកសារអមភ្ជាប់ដូចមានចែងក្នុងឧបសម្ព័ន្ធ ២
- ផ្ទៀងផ្ទាត់ឡើងវិញនូវភាពគ្រប់គ្រាន់និងត្រឹមត្រូវនូវរាល់ទិន្នន័យដែលបានបំពេញរួច មុននឹងដាក់ស្នើសុំចុះបញ្ជី បន្ទាប់មកអ្នកស្នើសុំត្រូវចុច "**ដាក់ស្នើ**" ដើម្បីទទួលបានលេខសំណើ ដែលនឹងបញ្ជូនបន្តដោយស្វ័យប្រវត្តិទៅមន្ត្រីគយនិងរដ្ឋាករទទួលបន្ទុក
- តាមដានជាប្រចាំនូវស្ថានភាពឯកសារស្នើសុំរបស់ខ្លួន តាមដំណាក់កាលនីមួយៗនៅក្នុងប្រព័ន្ធដោយផ្ទាល់ ឬតាមTelegram។ ក្នុងករណីមន្ត្រីទទួលបន្ទុក មានតម្រូវការក្នុងការផ្តល់បន្ថែមនូវព័ត៌មាននានា អ្នកស្នើសុំត្រូវផ្តល់ព័ត៌មានបញ្ជាក់ ឯកសារសំអាងនានា និង/ឬកែតម្រូវទិន្នន័យ រួចចុច"**ដាក់ស្នើ**" ឡើងវិញ។

## III. **ភារកិច្ច និងការទទួលខុសត្រូវរបស់មន្ត្រីគយនិងរដ្ឋាករមានសមត្ថកិច្ច**

### ក. ការពិនិត្យផ្ទៀងផ្ទាត់សំណើសុំ ដោយមន្ត្រីជំនាញទទួលបន្ទុក

១. ពិនិត្យភាពគ្រប់គ្រាន់ ត្រឹមត្រូវ និងភាពស៊ីចង្វាក់គ្នានៃឯកសារ ដូចជាវិក្កយបត្រ បញ្ជីវេចខ្ចប់ បណ្ណដឹកជញ្ជូន វិញ្ញាបនបត្រចុះបញ្ជីអាករលើតម្លៃបន្ថែម ប័ណ្ណប៉ាតង់ លិខិតផ្ទេរសិទ្ធិជាដើម។

២. ពិនិត្យនីតិសម្បទាបុគ្គលស្នើសុំ។

៣. ប្រសិនបើពុំឃើញមានភាពមិនប្រក្រតីទេ ត្រូវចុចទាញយកលិខិតសម្ភាសន៍ពីក្នុងប្រព័ន្ធ និងអញ្ជើញម្ចាស់ក្រុមហ៊ុន ឬតំណាងមកជួបសម្ភាសន៍។

៤. ប្រសិនបើពិនិត្យឃើញមានកំហុស ឬភាពមិនប្រក្រតីនានា ត្រូវកត់ត្រាអាទិសង្កេតស្តីពីកំហុស ឬភាពមិនប្រក្រតីនោះ រួចចុចលើប៊ូតុង "**បដិសេធ**" ដើម្បីបញ្ជូនសារទៅកាន់ Telegram ណែនាំឱ្យធុរជនឬដើងសាគយបញ្ជាក់ ឬផ្តល់ព័ត៌មានបន្ថែមតាមការចាំបាច់។

៥. នៅពេលម្ចាស់ក្រុមហ៊ុន ឬតំណាងផ្តល់ព័ត៌មានបន្ថែម ឬដាក់ស្នើសុំជាថ្មីនូវសំណើដែលបានកែតម្រូវរួច ត្រូវអនុវត្តដូចចំណុច "១" ខាងលើឡើងវិញ។

៦. បោះពុម្ពឯកសារសម្ភាសន៍ដែលត្រឹមត្រូវ និងគ្រប់គ្រាន់ ដើម្បីឱ្យម្ចាស់ក្រុមហ៊ុន ឬតំណាងផ្តិតមេដៃទទួលស្គាល់ និងស្កេនឯកសារនេះរក្សាទុកក្នុងប្រព័ន្ធវិញ។

៧. ចុចលើប៊ូតុង "**អនុម័ត**" ដើម្បីបញ្ជូនទៅកាន់មន្ត្រីពាក់ព័ន្ធផ្សេងទៀត បន្តនីតិវិធីផ្ទៀងផ្ទាត់។

៨. បំពេញទិន្នន័យនានាពីកំណត់ហេតុសូចនាករទៅក្នុងប្រព័ន្ធ TCMS នៅពេលឯកសារស្នើសុំត្រូវបានអនុម័ត ដោយប្រធាននាយកដ្ឋាន រួចរាល់។

### ខ. ការត្រួតពិនិត្យឡើងវិញសំណើសុំ ដោយប្រធានការិយាល័យ និងអនុប្រធាននាយកដ្ឋានទទួលបន្ទុក

១. ត្រូវពិនិត្យផ្ទៀងផ្ទាត់ឡើងវិញពីភាពគ្រប់គ្រាន់និងត្រឹមត្រូវនៃឯកសារក្នុងប្រព័ន្ធ ដែលបានផ្ទៀងផ្ទាត់រួចដោយមន្ត្រីទទួលបន្ទុក។

២. ប្រសិនបើពុំឃើញមានភាពមិនប្រក្រតីទេ ត្រូវចុចលើប៊ូតុង "**អនុម័ត**" ដើម្បីបញ្ជូនបន្ត។

៣. ប្រសិនបើពិនិត្យឃើញមានកំហុស ឬភាពមិនប្រក្រតីនានា ត្រូវកត់ត្រាអាទិសង្កេតស្តីពីកំហុស ឬភាពមិនប្រក្រតីនោះ រួចចុចលើប៊ូតុង "**បដិសេធ**" ដើម្បីបញ្ជូនសារទៅកាន់Telegram ណែនាំឱ្យធុរជនឬជើងសាគយបញ្ជាក់ ឬផ្តល់ព័ត៌មានបន្ថែមតាមការចាំបាច់។

៤. នៅពេលម្ចាស់ក្រុមហ៊ុន ឬតំណាងផ្តល់ព័ត៌មានបន្ថែម ឬដាក់ស្នើសុំជាថ្មីនូវសំណើដែលបានកែតម្រូវរួច ត្រូវអនុវត្តដូចចំណុច "១" ខាងលើឡើងវិញ។

**គ. ការសម្រេចសំណើសុំ ដោយប្រធាននាយកដ្ឋានសវនកម្មគយ តំណាង អគរ**

១. ត្រូវពិនិត្យផ្ទៀងផ្ទាត់ឡើងវិញពីភាពគ្រប់គ្រាន់និងត្រឹមត្រូវនៃឯកសារក្នុងប្រព័ន្ធ ដែលបានផ្ទៀងផ្ទាត់រួចដោយមន្ត្រីគយនិងរដ្ឋាករមានសមត្ថកិច្ច។

២. ប្រសិនបើពុំឃើញមានភាពមិនប្រក្រតីទេ ត្រូវចុចលើប៊ូតុង "**អនុម័ត**" ដើម្បីបញ្ជូនលិខិតបញ្ជាក់ពីការសម្រេចអនុញ្ញាតសំណើ ទៅធុរជនឬតំណាងតាម Telegram សម្រាប់បញ្ជាក់ពីការចុះបញ្ជីក្នុងប្រព័ន្ធ TCMS។

៣. ប្រសិនបើពិនិត្យឃើញមានកំហុស ឬភាពមិនប្រក្រតីនានា ត្រូវកត់ត្រាអាទិសង្កេតស្តីពីកំហុស ឬភាពមិនប្រក្រតីនោះ រួចចុចលើប៊ូតុង "**បដិសេធ**" ដើម្បីបញ្ជូនសារទៅកាន់តេឡេក្រាម ណែនាំឱ្យធុរជនឬតំណាងបញ្ជាក់ ឬផ្តល់ព័ត៌មានបន្ថែមតាមការចាំបាច់។

៤. នៅពេលម្ចាស់ក្រុមហ៊ុន ឬតំណាងផ្តល់ព័ត៌មានបន្ថែម ឬដាក់ស្នើសុំជាថ្មីនូវសំណើដែលបានកែតម្រូវរួច ត្រូវអនុវត្តដូចចំណុច "១" ខាងលើឡើងវិញ។

៥. អាចបដិសេធក្នុងការ មិនអនុម័ត ចេញលិខិតបញ្ជាក់ពីការចុះក្នុងបញ្ជីក្នុងប្រព័ន្ធ TCMS ក្នុងករណីពិនិត្យឃើញមានភាពមិនប្រក្រតី ឬមិនត្រឹមត្រូវដែលមិនអាចកែតម្រូវ ឬបំពេញបន្ថែមបាន ឬអាចបញ្ជាក់ថាម្ចាស់ក្រុមហ៊ុនមិនមែនជាម្ចាស់ពិតប្រាកដ និង/ឬមិនស្ថិតក្នុងកម្មវត្ថុនៃការផ្តល់លិខិតបញ្ជាក់។

**ឃ. ការទទួលខុសត្រូវរបស់អ្នកថែរក្សាប្រព័ន្ធ**

អ្នកជំនាញការ IT នៃការិយាល័យគ្រប់គ្រងហានិភ័យ និងការិយាល័យរដ្ឋបាលនិងគ្រប់គ្រង នៃនាយកដ្ឋានសវនកម្មគយ ត្រូវទទួលខុសត្រូវលើ៖

- ការអភិវឌ្ឍ កិច្ចដំណើរការ និងសុវត្ថិភាពនៃប្រព័ន្ធ
- រក្សាការសម្ងាត់នូវរាល់ព័ត៌មាន គណនីអ្នកប្រើប្រាស់ និងកំណត់ត្រានានាក្នុងប្រព័ន្ធទាំងមូល ប្រកបដោយការទទួលខុសត្រូវខ្ពស់
- ក្នុងករណីមានភាពមិនប្រក្រតីណាមួយត្រូវរាយការណ៍ជាបន្ទាន់មក នាយកដ្ឋានសវនកម្មគយ។

# ឧបសម្ព័ន្ធ ២

(អមភ្ជាប់លិខិតលេខ ៥៦៨៦/២៤ អគរ ចុះថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ២០២៤ របស់អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា)

## ឯកសារអមភ្ជាប់

រាល់ឯកសារអមភ្ជាប់ទាំងអស់ត្រូវស្ថិតក្នុងទម្រង់ pdf រីឯរូបថតត្រូវស្ថិតក្នុងទម្រង់ jpg ឬ jpeg ដែលស្កេនពីច្បាប់ដើម ហើយមានគុណភាពល្អ។ សូមបញ្ជាក់ថា ប្រសិនបើលោកអ្នកមិនផ្តល់ឯកសារឬព័ត៌មានគ្រប់គ្រាន់ និងច្បាស់លាស់ក្នុងពេលចុះបញ្ជីក្នុងប្រព័ន្ធ TCMS លោកអ្នកអាចនឹងប្រឈមការបដិសេធលើសំណើសុំចុះបញ្ជី។

១. <u>សម្រាប់សំណើសុំចុះបញ្ជីក្រុមហ៊ុនថ្មី៖</u>

- វិញ្ញាបនបត្របញ្ជាក់ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម ចំនួន ១ ច្បាប់
- ព័ត៌មានសម្រង់ក្រុមហ៊ុន (ក្រសួងពាណិជ្ជកម្ម) ចំនួន ១ ច្បាប់
- លក្ខន្តិកៈក្រុមហ៊ុន ចំនួន ១ ច្បាប់
- វិញ្ញាបនបត្រចុះបញ្ជីពន្ធដារ ចំនួន ១ ច្បាប់
- ប័ណ្ណប៉ាតង់ ឆ្នាំចុងក្រោយ ចំនួន ១ ច្បាប់
- ឯកសារពាក់ព័ន្ធការនាំចេញ-នាំចូល ដូចជា៖ វិក្កយបត្រ, បញ្ជីវេចខ្ចប់, និង/ឬ អញ្ញាតបណ្ណដឹកជញ្ជូន, កិច្ចសន្យាទិញ-លក់ ចំនួន១ច្បាប់
- លិខិតផ្ទេរសិទ្ធិ (ករណីប្រធានក្រុមហ៊ុនជាជនបរទេស) ចំនួន ១ ច្បាប់
- អត្តសញ្ញាណប័ណ្ណ ឬលិខិតឆ្លងដែនមានសុពលភាព របស់បុគ្គលស្នើសុំ និង បុគ្គលទទួលសិទ្ធិ (ករណីផ្ទេរសិទ្ធិ)ចំនួន ១ច្បាប់
- រូបថតស្លាកសញ្ញាសម្គាល់ក្រុមហ៊ុន/ឃ្លាំងស្តុកទំនិញ និងទីតាំងក្រុមហ៊ុន/ឃ្លាំងស្តុកទំនិញ រួមជាមួយរូបថតផែនទីបង្ហាញទីតាំងក្រុមហ៊ុន នៅលើ Google Maps ចំនួន ១ ច្បាប់
- កិច្ចសន្យាជួលទីតាំងក្រុមហ៊ុន/ឃ្លាំងស្តុកទំនិញ (បើមាន) ចំនួន ១ ច្បាប់
- កិច្ចសន្យាមិនផ្តល់សេវាកម្មនាំចេញ-នាំចូលជំនួសអ្នកដទៃ (ករណីការនាំចេញ-នាំចូលសម្រាប់គោលបំណងផ្ទាល់ខ្លួន តែមិនសមស្របនឹងសកម្មភាពអាជីវកម្មចម្បង) ចំនួន ១ ច្បាប់
- លិខិតអនុញ្ញាត ឬអាជ្ញាប័ណ្ណពីក្រសួង-ស្ថាប័នពាក់ព័ន្ធ (ករណីតម្រូវ) ចំនួន ១ ច្បាប់
- **<u>ឯកសារបន្ថែម</u>** ចំពោះក្រុមហ៊ុនគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ (QIP) ៖
  - ច្បាប់សាងសង់អគាររោងចក្រដែលមានការអនុញ្ញាតពីក្រសួង-ស្ថាប័នពាក់ព័ន្ធ (ករណីសាងសង់ថ្មី) ចំនួន ១ ច្បាប់
  - ករណីទិញឬជួលរោងចក្រមានស្រាប់៖ (១)កិច្ចសន្យាទិញ ឬជួលរោងចក្រ និង (២)លិខិតអនុញ្ញាតផ្ទេរគ្រឿងម៉ាស៊ីន សម្ភារៈបរិក្ខានានា និងវត្ថុធាតុដើម (បើមាន)
  - លិខិតអនុញ្ញាតនិងបញ្ជីមេពីក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា (CDC)
- ឯកសារផ្សេងទៀត (បើមាន ឬតម្រូវដោយមន្ត្រីគយនិងរដ្ឋាករមានសមត្ថកិច្ច)។

២. <u>សម្រាប់សំណើសុំដកចេញពីបញ្ជីធុរជនរកមិនឃើញ (UNKNOWN)</u>

- បច្ចុប្បន្នភាពនៃឯកសារពាក់ព័ន្ធ ក្នុងចំណុច ១. ខាងលើ (បើមាន)
- លិខិតផ្លាស់ប្តូរទីតាំង (បើមាន)
- លិខិតបំភ្លឺមូលហេតុដែលជាប់ Unknown
- លិខិតបញ្ជាក់ការបង់ប្រាក់ពន្ធប្រចាំខែនៅអគ្គនាយកដ្ឋានពន្ធដារសម្រាប់រយៈពេល ១២ ខែចុងក្រោយ។

# ឧបសម្ព័ន្ធ ៣

(អមភ្ជាប់លិខិតលេខ...៥៦៩៧/២៤...អគរ ចុះថ្ងៃទី...៣១.......ខែធ្នូ ឆ្នាំ២០២៤ របស់អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា)

## ដំណើរការនៃកាចុះបញ្ជីធុរជនក្នុងទម្រង់អេឡិចត្រូនិកតាម ប្រព័ន្ធគ្រប់គ្រងភាពជឿជាក់លើធុរជនជំនាន់ថ្មី

**១.** បង្កើតគណនីលើអាសយដ្ឋាន https://rm.customs.gov.kh/TCMS

**២.** Login ចូលអាសយដ្ឋាន https://rm.customs.gov.kh/TCMS រួចជ្រើសរើសប្រភេទសំណើ

**៣.** ដំណើរការចុះបញ្ជីក្នុងប្រព័ន្ធ

**៤.** ពិនិត្យស្ថានភាព និងទទួលបានសារជូនដំណឹងពីកំហុសផ្សេងៗក្នុងដំណាលកាលនីមួយៗ តាមរយៈ Telegram

**៥.** ទទួលលិខិតបញ្ជាក់ពីការចុះបញ្ជី។

**សម្រាប់ព័ត៌មានបន្ថែម៖**

១. លោក ស សារ៉ាត់ (០១៧ ៩៩៩ ២១៧)

២. លោកស្រី ព្រំ បុប្ផារ័ត្ន (០៧៧ ៦៨២ ៨០១)

*<u>ស្កេនដើម្បីទាញយកឯកសារពាក់ព័ន្ធ</u>*

# ឧបសម្ព័ន្ធ ៤

(អមភ្ជាប់លិខិតលេខ ...៤៦៩២/២៤...អគរ ចុះថ្ងៃទី៣១... ខែធ្នូ ឆ្នាំ២០២៤ របស់អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា)

## ១.គំរូសំណើសុំចុះបញ្ជីថ្មី

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

| នាយកដ្ឋានសវនកម្មគយ | |
|---|---|
| ចូល | លេខ 2<br>ថ្ងៃទី 11-Jan-2025<br>ម៉ោង 8:26 am |

នាមករណ៍ក្រុមហ៊ុន ៖ ABCDEFG MNOP CO., LTD.
លេខ អតប ៖ K009123456789
អាសយដ្ឋាន៖ 434, STREET PHLOV LUM, PHUM PREY KHLA, KHUM POU ANGKRANG. SROK BASEDTH. KAMPONG SPEU PROVINCE

**សូមគោរពជូន**

**លោកប្រធាននាយកដ្ឋានសវនកម្មគយ នៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា**

**កម្មវត្ថុ ៖** សំណើសុំបញ្ចូលឈ្មោះក្រុមហ៊ុនក្នុងប្រព័ន្ធគ្រប់គ្រងភាពជឿជាក់លើធុរជន (TCMS) ដើម្បីបំពេញបែបបទបញ្ចេញទំនិញពីគយ។

**យោង ៖**
- Invoice លេខ 3434 ចុះថ្ងៃ 15-Nov-2023
- Bill of Lading លេខ 3434 ចុះថ្ងៃ 15-Nov-2023
- វិញ្ញាបនបត្រចុះបញ្ជីអាករលើតម្លៃបន្ថែម លេខ 3434 ចុះថ្ងៃ 15-Nov-2023
- វិញ្ញាបនត្ររបស់ក្រសួងពាណិជ្ជកម្ម លេខ 3434 ចុះថ្ងៃ 15-Nov-2023។

តបតាមកម្មវត្ថុនិងយោងខាងលើ ខ្ញុំបាទ/នាងខ្ញុំមានកិត្តិយសសូមជម្រាបជូនលោកប្រធាននាយកដ្ឋានមេត្តាជ្រាបថា ក្រុមហ៊ុនយើងខ្ញុំទើបបើកដំណើរការនាពេលថ្មីៗនេះ និងទើបត្រូវបានទទួលស្គាល់ជានីតិបុគ្គលស្របច្បាប់ពីក្រសួងពាណិជ្ជកម្ម ព្រមទាំងបានទទួលលេខអត្តសញ្ញាណកម្ម អតប ពីអគ្គនាយកដ្ឋានពន្ធដាររួចហើយ។

ខ្ញុំសូមបញ្ជាក់ថា ក្រុមហ៊ុនយើងខ្ញុំមានទីតាំងច្បាស់លាស់ និងមានលើកស្លាកសម្គាល់ត្រឹមត្រូវតាមអាសយដ្ឋាន434, STREET PHLOV LUM, PHUM PREY KHLA, KHUM POU ANGKRANG, SROK BASEDTH, KAMPONG SPEU PROVINCE ។ ក្រុមហ៊ុនសូមសន្យាថានឹងបំពេញកាតព្វកិច្ចផ្សេងៗទៀតតាមបទប្បញ្ញត្តិជាធរមាន។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមលោកប្រធាននាយកដ្ឋានសវនកម្មគយមេត្តាពិនិត្យ និងសម្រេច ដោយក្តីអនុគ្រោះ។

សូមលោកប្រធាននាយកដ្ឋានសវនកម្មគយ ទទួលនូវការគោរពពីយើងខ្ញុំ

ខេត្តកំពង់ស្ពឺ ថ្ងៃទី11 ខែមករា ឆ្នាំ2025
ប្រធានក្រុមហ៊ុន

MANAGER'S NAME

Page 1 of 1

# ២.គំរូសំណើសុំដកចេញពីបញ្ជីធុរជនរកមិនឃើញ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

| នាយកដ្ឋានសវនកម្មគយ | |
|---|---|
| ចូល | លេខ 2<br>ថ្ងៃទី 11-Jan-2025<br>ម៉ោង 8:26 am |

នាមករណ៍ក្រុមហ៊ុន ៖ ABCDEFG MNOP CO., LTD.

លេខ អតប ៖ K009123456789

អាសយដ្ឋាន៖ 434, STREET PHLOV LUM, PHUM PREY KHLA, KHUM POU ANGKRANG, SROK BASEDTH, KAMPONG SPEU PROVINCE

**សូមគោរពជូន**

**លោកប្រធាននាយកដ្ឋានសវនកម្មគយ នៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា**

**កម្មវត្ថុ ៖** សំណើសុំបញ្ចូលឈ្មោះក្រុមហ៊ុនក្នុងប្រព័ន្ធគ្រប់គ្រងភាពជឿជាក់លើធុរជន (TCMS) ដើម្បីបំពេញបែបបទបញ្ចេញទំនិញពីគយ។

**យោង ៖**
- Invoice លេខ 3434 ចុះថ្ងៃ 15-Nov-2023
- Bill of Lading លេខ 3434 ចុះថ្ងៃ 15-Nov-2023
- វិញ្ញាបនបត្រចុះបញ្ជីអាករលើតម្លៃបន្ថែម លេខ 3434 ចុះថ្ងៃ 15-Nov-2023
- វិញ្ញាបនត្ររបស់ក្រសួងពាណិជ្ជកម្ម លេខ 3434 ចុះថ្ងៃ 15-Nov-2023។

តបតាមកម្មវត្ថុនិងយោងខាងលើ ខ្ញុំបាទ/នាងខ្ញុំមានកិត្តិយសសូមជម្រាបជូនលោកប្រធាននាយកដ្ឋានមេត្តាជ្រាបថា ក្រុមហ៊ុនយើងខ្ញុំទើបបើកដំណើរការនាពេលថ្មីៗនេះ និងទើបត្រូវបានទទួលស្គាល់ជានីតិបុគ្គលស្របច្បាប់ពីក្រសួងពាណិជ្ជកម្ម ព្រមទាំងបានទទួលលេខអត្តសញ្ញាណកម្ម អតប ពីអគ្គនាយកដ្ឋានពន្ធដាររួចហើយ។

ខ្ញុំសូមបញ្ជាក់ថា ក្រុមហ៊ុនយើងខ្ញុំមានទីតាំងច្បាស់លាស់ និងមានលើកស្លាកសម្គាល់ត្រឹមត្រូវតាមអាសយដ្ឋាន434, STREET PHLOV LUM, PHUM PREY KHLA, KHUM POU ANGKRANG, SROK BASEDTH, KAMPONG SPEU PROVINCE ។ ក្រុមហ៊ុនសូមសន្យាថានឹងបំពេញកាតព្វកិច្ចផ្សេងៗទៀតតាមបទប្បញ្ញត្តិជាធរមាន។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមលោកប្រធាននាយកដ្ឋានសវនកម្មគយមេត្តាពិនិត្យ និងសម្រេច ដោយក្តីអនុគ្រោះ។

សូមលោកប្រធាននាយកដ្ឋានសវនកម្មគយ ទទួលនូវការគោរពពីយើងខ្ញុំ

ខេត្តកំពង់ស្ពឺ ថ្ងៃទី11 ខែមករា ឆ្នាំ2025

ប្រធានក្រុមហ៊ុន

**MANAGER'S NAME**

# ៣.គំរូលិខិតបញ្ជាក់ការចុះបញ្ជីធុរជនក្នុងប្រព័ន្ធគ្រប់គ្រងភាពជឿជាក់លើធុរជន

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា

| នាយកដ្ឋានសវនកម្មគយ | |
|---|---|
| **ចេញ** | លេខ 5<br>ចុះថ្ងៃ 08-April-2024<br>ម៉ោង 8:11PM |

## លិខិតបញ្ជាក់ការចុះបញ្ជីធុរជនក្នុងប្រព័ន្ធគ្រប់គ្រងភាពជឿជាក់លើធុរជន (TCMS)

| | |
|---|---|
| នាមករណ៍ក្រុមហ៊ុន៖<br>ABC ABCDEDFG CO., LTD.<br><br>លេខ អតប ៖ L001123456789 | អាសយដ្ឋាន៖<br>353, STREET 443, PHUM SRAE KHNHER, KHUM POU MREAL, SROK BASEDTH, KAMPONG SPEU PROVINCE |
| លេខទូរស័ព្ទ៖ 3434 34 | កាលបរិច្ឆេទបើកដំណើរការក្រុមហ៊ុន ៖ 18-April-2024 |

ឯកសារភ្ជាប់៖

- Invoice លេខ 343 ចុះថ្ងៃ 01-Apr-2024
- Bill of Lading លេខ 343 ចុះថ្ងៃ 01-Apr-2024
- វិញ្ញាបនបត្រចុះបញ្ជីអាករលើតម្លៃបន្ថែម លេខ 343 ចុះថ្ងៃ 01-Apr-2024
- វិញ្ញាបនបត្ររបស់ក្រសួងពាណិជ្ជកម្ម លេខ 343 ចុះថ្ងៃ 01-Apr-2024។

- អនុញ្ញាតឱ្យបញ្ចូលក្នុងប្រព័ន្ធគ្រប់គ្រងភាពជឿជាក់លើធុរជន (TCMS)
- ការិយាល័យគយនិងរដ្ឋាករពាក់ព័ន្ធសម្រួលអនុញ្ញាតពិនិត្យបែបបទគយ តាមបទប្បញ្ញត្តិជាធរមាន។

កំណត់សម្គាល់៖

រាជធានីភ្នំពេញ, ថ្ងៃទី០៨ ខែមេសា ឆ្នាំ២០២៤
**តប.រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី**
**អគ្គនាយកគយនិងរដ្ឋាករកម្ពុជា**
**ប្រធាននាយកដ្ឋានសវនកម្មគយ**

(សំណើលេខ 3 ចុះថ្ងៃ 06-April-2024)

# ៤.គំរូលិខិតបញ្ជាក់ការសម្រេចឱ្យដកចេញពីបញ្ជីធុរជនរកមិនឃើញ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា

| នាយកដ្ឋានសវនកម្មគយ | |
|---|---|
| ចេញ | លេខ 7<br>ចុះថ្ងៃ 09-April-2024<br>ម៉ោង 5:06PM |

## លិខិតបញ្ជាក់ការសម្រេចឱ្យដកចេញពីបញ្ជីធុរជនរកមិនឃើញ

| | |
|---|---|
| នាមករណ៍ក្រុមហ៊ុន៖<br>ABC ABCDEDFG CO., LTD.<br><br>លេខ អតប ៖ L001123456789 | អាសយដ្ឋាន៖<br>453, STREET 598, PHUM KANTUOT, SANGKAT KDOL DOUN TEAV, KRONG BATTAMBANG, BATTAMBANG PROVINCE |
| លេខទូរស័ព្ទ៖ 0232552332 012669535 | កាលបរិច្ឆេទបើកដំណើរការក្រុមហ៊ុន ៖ 09-April-2024 |
| ឯកសារភ្ជាប់៖<br>- Invoice លេខ 43243 ចុះថ្ងៃ 01-Apr-2024<br>- Bill of Lading លេខ 43243FDSFSE34 ចុះថ្ងៃ 09-Apr-2024<br>- វិញ្ញាបនបត្រចុះបញ្ជីអាករលើតម្លៃបន្ថែម លេខ 34343FDF ចុះថ្ងៃ 09-Apr-2024<br>- វិញ្ញាបនបត្ររបស់ក្រសួងពាណិជ្ជកម្ម លេខ 3432FDF ចុះថ្ងៃ 08-Apr-2024។ | |
| - អនុញ្ញាតឱ្យដកចេញពីបញ្ជីធុរជនរកមិនឃើញ<br>- ការិយាល័យគយនិងរដ្ឋាករពាក់ព័ន្ធសម្រួលអនុញ្ញាតពិនិត្យបែបបទគយ តាមបទប្បញ្ញត្តិជាធរមាន។ | |
| កំណត់សម្គាល់៖ | |

រាជធានីភ្នំពេញ, ថ្ងៃទី០៩ ខែមេសា ឆ្នាំ២០២៤
តប.រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី
អគ្គនាយកគយនិងរដ្ឋាករកម្ពុជា
ប្រធាននាយកដ្ឋានសវនកម្មគយ

( សំណើលេខ 5 ចុះថ្ងៃ 09-April-2024 )